# Living the Lotus

## Buddhism in Everyday Life

5
2024
VOL. 224










Rissho Kosei-kai of Seattle






















**Living the Lotus**
**Vol. 224 (May 2023)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.



TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិករីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



# មនុស្សទន់ភ្លន់ មានបេះដូងសេរី

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## ដោះគោចេញពីនឹម

រាល់ឆ្នាំឱ្យតែដល់រដូវកាលនេះខ្ញុំព្រះករុណាអាត្មាភាពតែងតែរំលឹកឃើញកាលពីនៅជាកុមារដែលត្រូវជួយឪពុកម្ដាយជាកសិករ កាប់ឆ្ការភ្លូររាស់ពង្រាបដីធ្វើស្រែចំការដើម្បីសាបព្រោះស្រូវឬដាំដំណាំ។កាលនោះខ្ញុំព្រះករុ ណាអាត្មាភាពនៅជាសិស្សសាលាបឋមសិក្សាថ្នាក់ទី៥-៦ ឬក៏ជាសិស្សមធ្យមថ្នាក់ទី១ ឬទី២ នៅពេលភ្ជួរស្រែ តែងតែយកខ្សែទៅចង "ច្រមុះគោ (បើខ្មែរគេដាក់កន្លះ) ហើយអូស" វាឱ្យវាដើរទៅមុខ។ នៅពេលនោះគោវាបញ្ចេញខ្យល់ខ្លាំងៗតាមច្រមុះមកឮសូរតែ "វ៉ាស" ដាក់ខ្ញុំព្រះករុណាអាត្មាភាពធ្វើឱ្យខ្ញុំព្រះករុណាអាត្មាភាពភិតភ័យតក់ស្លុតពន់ពេក។ក៏ប៉ុន្តែគោឬសេះនោះក៏ជាសមាជិកម្នាក់ដ៏ថ្លៃថ្លាដែលរស់នៅក្រោមដំបូលតែមួយនៃគ្រួសាររបស់យើង ។

នៅពេលដែលខ្ញុំព្រះករុណាអាត្មាភាពទៅលេងផ្ទះកំណើតរបស់កៃសូសាម៉ាដែលនៅឯស្រុកស៊ីហ្កានុម៉ាខេត្តនីហ្កាតាជាលើកដំបូង  ពេលបើកទ្វារផ្ទះខ្វាក ហើយឈានជើងចូលទៅក្នុងមាត់ទ្វារដ៏ងងឹតសូន្យនោះខ្ញុំព្រះករុ ណាអាត្មាភាពនៅចាំច្បាស់ថាមានក្លិនដែលភាយចេញពីក្រោលគោក្រោលសេះមក។

ចំពោះខ្ញុំព្រះករុណាអាត្មាភាពដែលមានទម្លាប់រស់នៅជិតស្និទ្ធជាមួយនឹងគោឬសេះខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ថាគម្ពីរ "សុត្តនិបថា" ដែលប្រមូលផ្ដុំព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធនោះ មានល្បះមួយឃ្លាគឺ  "ដែលហៅថាទន់ភ្លន់គឺ ដោះគោចេញពីនឹម" ។ មួយល្បះនេះនាំឱ្យខ្ញុំព្រះករុណាអា ត្មាភាពនឹកដល់ទំនាក់ទំនងជាមួយនឹងគោឬសេះដែលយើងចិញ្ចឹម ហើយនាំឱ្យខ្ញុំព្រះករុ ណាអាត្មាភាពមានអារម្មណ៍ថាឃ្លាមួយនេះវាបន្តផ្ជាប់ទៅនឹងសមានចិត្តរបស់មនុស្សយ៉ាងតឹងណែន។នៅពេលដែលឈប់ភ្ជួរស្រែហើយដោះគោចេញពីនឹមក៏កើតឱ្យមានចិត្តចង់លួងលោមវាថា "មួយថ្ងៃនេះឯងបានជួយធ្វើការច្រើនណាស់អរគុណហើយ" ។គឺជាពាក្យ

សម្ដែងចិត្តអរគុណក៏ពិតមែនហើយក៏ប៉ុន្តែជាពាក្យដែលបង្ហាញ "សភាពការស្លូតបូតទន់ភ្លន់" ។នេះបើរម្ងាស់វាឱ្យខះទៅនឹងនៅសល់តែពាក្យ "ទន់ភ្លន់"  តែមួយម៉ាត់ ដូចជាសមានចិត្តដែលកសិករមានទៅលើសត្វគោដែលជាសមាជិកគ្រួសារម្នាក់ដែរគឺថាមនុស្សតោងតែមានចិត្ត "ទន់ភ្លន់" ជាមួយនឹងគ្រប់មនុស្សហើយសេចក្ដីប្រាថ្នារបស់ព្រះសម្មាសម្ពុទ្ធមានបង្កប់នៅក្នុងនោះឯង។

## ប្រសិនបើអាចលះបង់ចិត្តជាប់ជំពាក់ឬប្រ កាន់បាន

ពាក្យថា “ដោះគោចេញពីនឹម” នេះបើយើងមើលពីជ្រុងជ្រោយផ្សេងវិញគឺបង្រៀនបែបនិមិត្តរូបឱ្យយើងជាមនុស្សគិតថា “រស់ដោយដកខ្លួនចេញពីចំណងនានាដែលចងក្រៀកយើងជាការប្រសើរ” ។

មនុស្សតែងតែមានសេចក្តីរំពឹងទុកឬមួយក៏មានការជាប់ជំពាក់ទៅនឹងអ្វីៗដ៏ច្រើនមិនអាចរស់ដូចសត្វឬរុក្ខជាតិដែលមិនមានជំពាក់ជំពិនឬប្រកាន់ហើយរស់ដោយសេរីបានទេ។ដោយសារតែការជំពាក់ជំពិននោះទុក្ខសោកក៏កើតមាន។ទោះជាមិនបានទៅដល់ចិត្តមិនខ្វល់ខ្វាយ ចិត្តដែលសេរីដូចព្រះពុទ្ធពោធិសត្វក្តីក៏មនុស្សណាម្នាក់ក៏ប្រាថ្នាឱ្យបានចាកផុតពីការជាប់ជំពាក់ទោះបីជាបន្តិចបន្តួចក្តីឬក៏កុំឱ្យស្ងួរម្ងួរម៉ៅហើយរស់ដោយភាពរីករាយសប្បា យចិត្តដែរ។

នៅសម័យអេដូ (1603－1868) មានព្រះសង្ឃហ្សេងមួយអង្គព្រះនាមស៊ីដូប៊ឺណាំង។លោកតែងតែមានព្រះសង្ឃដីកាថា “មិនគិតអ្វីសោះ គឺការហាត់រៀនធ្វើព្រះពុទ្ធ” “មានឥរិយាបថដូចជាមិនគិតអ្វីហើយស្អីក៏ធ្វើស្អីក៏ធ្វើ” ។ គឺព្រះអង្គតែងតែខំធ្វើយ៉ាងណាកុំឱ្យគិត។មានរឿងមួយកើតឡើងដូចខាងក្រោមនេះ។

មានបុរសចំណាស់ដែលមានទ្រព្យស្តុកស្តម ម្នាក់ស្រឡាញ់គោរពព្រះសង្ឃហ្សេងព្រះនាមស៊ីដូប៊ឺណាំងនោះខ្លាំងពេកក៏សង់អាស្រមប្រគេនដើម្បីចងលោកទុកកុំឱ្យលោកនិមន្តទៅណា ឱ្យនៅក្នុងភូមិរបស់គាត់។ថ្ងៃមួយគាត់បានដឹងថាកូនស្រីរបស់គាត់មានផ្ទៃពោះ គាត់ក៏សួរនាំដេញដោលឱ្យកូនស្រីគាត់ប្រាប់ពីឈ្មោះឪពុកទារក។កូនស្រីនោះក៏ឆ្លើយភូតភរកុហកថា “ព្រះសង្ឃហ្សេង” ។បុរសចំ ណាស់ខឹងជ្រុលពេកក៏ស្ទុះសស្លើតសស្លក់ទៅអាស្រមព្រះសង្ឃជេរត្មះតិះដៀលលោកជាដំណំហើយដេញលោកចេញពីភូមិ។

លុះបានបន្តិចទៅនាងជាកូនស្រីក៏ទម្លាយប្រាប់ឪពុកពីការពិតថា “ ដោយនាងខ្លាចឪពុកស្តីបន្ទោសទើបកុហកថាព្រះសង្ឃជាអ្នកធ្វើឱ្យនាងមានផ្ទៃពោះព្រោះនាងឃើញឪពុកគោរពស្រឡាញ់ព្រះសង្ឃប្រហែលជាឪពុកមិនចាប់ទោសពៃរ៍នាងទេ” ។

បុរសចំណាស់ប្រញិបប្រញាប់រត់ទៅអាស្រមព្រះសង្ឃហើយសុំអនុញ្ញាតទោសពីលោកទាំងទឹកភ្នែកសស្រិកសស្រាក់។ព្រះសង្ឃបានសរសេរទុកក្នុងកំណត់ហេតុរបស់លោកថា៖ “សើចហះៗហាឱ្យខ្លាំងៗទៅសូម្បីតែទឹកសន្សើមក៏មិនទៅស្តីបន្ទោសអ្នកដែរ” ។ បើសួរឱ្យរកនរណាម្នាក់ដែលជាបុគ្គលមានចិត្តមេត្តាករុណា ទន់ភ្លន់នោះចម្លើយគឺគ្មាននរណាក្រៅពីព្រះសង្ឃហ្សេងស៊ីដូប៊ឺណាំងឡើយ។

នៅក្នុងការពិតជាក់ស្តែង “ស៊ីដូប៊ឺណាំង” ជាពាក្យនៅក្នុងព្រះពុទ្ធសាសនាហ្សេងដែលមានន័យថា “មាគ៌ាដើម្បីឱ្យបានទៅដល់សច្ចធម៌គ្មានអ្វីពិបាកទេ” ។គ្រាន់តែថាធ្វើម៉េចកុំឱ្យខ្លួនឯងនេះជាប់ជំពាក់ដូចជាថានោះចូលចិត្ត នោះមិនចូលចិត្តទេ ទៅបានហើយ។នេះហើយដែលហៅថាមាគ៌ាព្រះពុទ្ធ។

បើនិយាយពីពាក្យថាទន់ភ្លន់ កៃស្ងសាម៉ាបានមានសង្ឃដីកាថា “ដើមដំបូងគ្រាន់តែធ្វើឱ្យខាងក្រៅឃើញថាជាមនុស្សញញឹមនិយមទទេក៏បានដែរ។បន្ទាប់មកខិតខំធ្វើចិត្តយើងឱ្យទន់ភ្លន់ទៅចិត្តនោះវានឹងរលាយចូលទៅជាមួយនឹងស្មារតីរបស់យើងជាស្វ័យប្រវត្តិហើយ” ។ដូច្នេះប្រសិនបើប្រាថ្នាចង់ទៅជាមនុស្សដែលទន់ភ្លន់ហើយសេរីដូចព្រះពុទ្ធចូរប្រាថ្នាក្នុងចិត្តហើយធ្វើមុខញញឹមញញែមទទួលយកនូវអ្វីៗដែលចូលមកដល់ខ្លួនតាម តែអាចធ្វើទៅបាន។



“កូសេ” លេខខែឧសភាឆ្នាំ២០២៤

# Rissho Kosei-kai International

**Make Every Encounter Matter**



## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**twitter**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp